« សេចក្ដីស្រឡាញ់កើតឡើង ដោយសារតែការថេះ អភ័យទោសដល់អ្នកដទៃ » ។



នៅពេលពួកអ្នកផ្សព្វផ្សាយសាសនាបានមកដល់ ជូលៀ បានស្វាគមន៍ពួកគេឲ្យចូលក្នុង ។ អ្នកផ្សព្វផ្សាយសាសនាម្នាក់បានឃើញរូបថតមួយសន្លឹកនៅលើធ្នើរឡឿង ។ វាគឺជារូបថតអាពាហ៍ពិពាហ៍របស់ជូលៀ ។

ផ្សព្វផ្សាយសាសនានោះបានសួរ ហើយចង្អុលទៅរូបថតនោះថា « នរណាគេក្នុងរូបថតនោះ ? »

ជូលៀ បានសម្លឹងចុះក្រោមឆ្លើយថា « បងចន ជាស្វាមីរបស់ខ្ញុំ » ។ « គាត់បានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ » ។

អ្នកផ្សព្វផ្សាយសាសនាបានងក់ក្បាល ។ « យើងជឿថាក្រុមគ្រួសារអាចរស់នៅជាមួយគ្នាជានិរន្តរ៍សូម្បីតែក្រោយពេលដែលពួកគេបានស្លាប់ទៅហើយក្ដី » ។

អារម្មណ៍នៃសេចក្ដីសុខសាន្តបានគ្របដណ្ដប់លើ ជូលៀ ។ គាត់មានអារម្មណ៍សប្បាយចិត្តដើម្បី រៀនអំពីផែនការរបស់ព្រះ ហើយបន្តជួបជាមួយពួកអ្នកផ្សព្វផ្សាយសាសនា ។ សេចក្ដីស្រឡាញ់ចំពោះដំណឹងល្អដែលបានរីកលូតលាស់នៅក្នុងដួងចិត្តរបស់ ជូលៀ គឺដូចជារុក្ខជាតិដុះនៅក្នុងសួនដំណាំរបស់គាត់ដូច្នោះដែរ ។ មិនយូរប៉ុន្មាន គាត់បានសម្រេចចិត្តទទួលបុណ្យជ្រមុជ ទឹក ។

នៅក្នុងព្រះវិហារ ជូលៀ បានជួបមនុស្សថ្មីៗជាច្រើន ។ ពួកគេខ្លះជាពលរដ្ឋស្បែកខ្មៅ ។ ពួកគេខ្លះជាពលរដ្ឋស្បែកស ។ ប៉ុន្តែពួកគេទាំងអស់បានបម្រើ និងបានរៀនជាមួយ គ្នា ។

ជូលៀ បានបង្ហាញដល់កុមារនៅព្រះវិហារអំពីរបៀបជួយនៅក្នុងសួនរបស់គាត់ ។ គាត់បាននិយាយថា « យើងត្រូវតែមានដួងចិត្តទន់ភ្លន់ ដូចជាដីនេះអញ្ចឹង » ។ « យើងត្រូវតែទុកកន្លែងមួយឲ្យដំណឹងល្អនៅជាមួយយើង ។ យើងត្រូវតែមានកន្លែងសម្រាប់សេចក្ដីស្រឡាញ់ » ។ ●